00275534

**Declassified to Public**
**06 September 2012**

E21/31/3

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
29 / 01 / 2009
ម៉ោង (Time/Heure): 15:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

## ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
29 / 01 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឈ្មោះ: លោកស្រី ញឹក ដារី
ថ្ងៃ/ខែ/ឆ្នាំកំណើត: ២៦ ធ្នូ ១៩៤៧
តំណាងដោយ: លោក ហុង គឹមសួន និង លោក Pierre-Olivier SUR
អាសយដ្ឋាន: ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា No.12, St. 282, បឹងកេងកង I, ភ្នំពេញ
យោងសំណុំរឿងលេខ: ០០១/១៨ កក្កដា ឆ្នាំ ២០០៧/អវតក/អជសដ

**កម្មវត្ថុ: ការទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីបណ្តោះអាសន្ន**

១. ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង បានទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រី ហើយពាក្យសុំនេះបានដាក់បញ្ចូលក្នុងសំណុំរឿងរួចហើយ ដូចដែលបានបញ្ជាក់ខាងលើតាមបញ្ជាពីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ។

២. ជាវិធានការបណ្តោះអាសន្ន លោកស្រីត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការនីតិវិធីរហូតដល់សវនាការបឋមនៅក្នុងរឿងក្តីនេះ ដែលនៅពេលនោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រី នឹងត្រូវលើកយកមកពិចារណាស្របតាមបញ្ញត្តិនៃវិធាន៨៣។

**ការតំណាងតាមផ្លូវច្បាប់**

៣. លើសពីនេះទៅទៀត ក្រឡាបញ្ជីក៏បានទទួលផងដែរនូវការចង្អុលបង្ហាញរបស់លោកស្រី ដែលចង់ឱ្យ លោក ហុង គឹមសួន និង លោក Pierre-Olivier SUR ធ្វើជាអ្នកតំណាងដែលច្បាប់បានកំណត់នៅក្នុងរឿងក្តីនេះ ហើយលិខិតផ្ទេរសិទ្ធិតំណាងដោយអាណត្តិពាក់ព័ន្ធក៏បានភ្ជាប់មកជាមួយផងដែរ ។

*E.C.C.C. TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE C.E.T.C.*

ដូច្នេះ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអង្គជំនុំជម្រះសាលាដំបូង ឬកំណត់ដោយវិធានផ្ទៃក្នុង ការចូលរួមណាមួយជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវធ្វើតាមរយៈមេធាវីរបស់លោកស្រី ។

**អំណាចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការប្រកាសមិនទទួលយកនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

៤. អង្គជំនុំជម្រះសាលាដំបូងអាចធ្វើសេចក្តីសម្រេចជាផ្លូវការក្នុងការទទួលយក នូវពាក្យសុំរបស់លោកស្រី ហើយក៏អាចបដិសេធចោលផងដែរនូវពាក្យសុំនេះ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាពាក្យសុំរបស់លោកស្រី មិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យតាមផ្លូវច្បាប់ថាជាជនរងគ្រោះ ដូចដែលបានចែងក្នុងវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីអំពីការចូលរួមនៃជនរងគ្រោះ។

**ការគោរពគោលការណ៍នៃការរក្សាការសម្ងាត់**

៥. លោកស្រីត្រូវដឹងថា តាមរយៈការចូលរួមរបស់លោកស្រីជាភាគីដើមបណ្តឹងរដ្ឋប្បវេណី លោកមេធាវីរបស់លោកស្រី និង/ឬបុគ្គលផ្សេងទៀតដែលជួយដល់លោកស្រីអាចទទួលបានព័ត៌មានសម្ងាត់ដែលមាន នៅក្នុងសំណុំរឿងបាន។ មានតែចៅក្រមនៃ អ.វ.ត.ក ប៉ុណ្ណោះ ដែលអាចសម្រេចបានថាព័ត៌មានខាងលើជាព័ត៌មានសាធារណៈ។ លោកស្រីនិងមេធាវីទាំងអស់ត្រូវមានកាតព្វកិច្ចមិនឲ្យផ្សព្វផ្សាយនូវព័ត៌មានសម្ងាត់ទាំងនេះទេ ។

**ការជូនដំណឹងពីបញ្ជីឈ្មោះសាក្សី និងឯកសារផ្សេងៗ**

៦. ភ្ជាប់ជាមួយលិខិតនេះ មេធាវីរបស់លោកស្រីនឹងត្រូវទទួលបានការជូនដំណឹងអំពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ដែលសហព្រះរាជអាជ្ញាមានបំណងកោះហៅឲ្យចូលរួមក្នុងពេលសវនាការ ព្រមទាំងឯកសារដែលពាក់ព័ន្ធផ្សេងៗទៀត ។ តាមបញ្ញត្តិនៃវិធាន ៨០(២) នៃវិធានផ្ទៃក្នុង រាល់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានបំណងកោះហៅសាក្សី ឬអ្នកជំនាញណាមួយដែលមិនមានឈ្មោះក្នុងបញ្ជីដែលផ្តល់ឲ្យដោយសហព្រះរាជអាជ្ញា ត្រូវដាក់បញ្ជីឈ្មោះសាក្សីបន្ថែមក្នុងរយៈពេល ១៥ ថ្ងៃ គិតចាប់ពីថ្ងៃទទួលដំណឹងនៃបញ្ជីឈ្មោះសាក្សីរបស់សហព្រះរាជអាជ្ញានេះ ។

**ការទទួលបានព័ត៌មានបន្ថែម**

៧. ប្រសិនលោកស្រីត្រូវការការណែនាំបន្ថែម ទាក់ទងនឹងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី សូមអញ្ជើញទំនាក់ទំនងជាមួយអង្គភាពជនរងគ្រោះ។ វិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមនៃជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក អាចជាឯកសារសម្រាប់ពិគ្រោះយោបល់ ដែលអ្នកសារទាំងនេះអាចទាញស្រង់ចេញពីគេហទំព័ររបស់អង្គភាពជនរងគ្រោះ(http://www.eccc.gov.kh/english/victims_unit.aspx)។

E2/31/3

០០១/១៨-០៧-២០០៧-អវតក/អជសង

ភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩

ក្រឡាបញ្ជី

ឌុច ផារី                    Matteo CRIPPA